**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីកូវីដមានវីរុសកូវីដ-១៩ ថ្មី ចំនួន ០៣នាក់ នៅក្នុងព្រឹត្តិការណ៍ ០៣វិច្ឆិកា
## នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា លទ្ធផលវិភាគវត្ថុសំណាកលើកទី២ ជូនដល់អ្នកប៉ះពាល់នៅក្នុងព្រឹត្តិការណ៍០៣វិច្ឆិកា គិតត្រឹមម៉ោង០៥:០០ល្ងាចនៃថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលផ្តល់ដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានបង្ហាញពីការរកឃើញ **អ្នកវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០៣នាក់** ដែលមានដូចតទៅ៖

- ឯកឧត្តម សួស យ៉ារ៉ា ជនជាតិខ្មែរអាយុ ៥៧ឆ្នាំ ជាសមាជិករដ្ឋសភា មានអាសយដ្ឋាននៅខណ្ឌទួលគោក រាជធានីភ្នំពេញ
- លោក ស ចិត្រា ជនជាតិខ្មែរអាយុ ៥៧ឆ្នាំ ជាអគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ មានអាសយដ្ឋាននៅសង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ
- បុរសជនជាតិហុងគ្រីអាយុ ៦៨ឆ្នាំ ជាឯកអគ្គរដ្ឋទូតហុងគ្រីសម្រាប់កម្ពុជា និងវៀតណាម ស្នាក់នៅសណ្ឋាគារមួយក្នុងទីក្រុងភ្នំពេញ។

បច្ចុប្បន្ន អ្នកជំងឺខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

សូមកត់សម្គាល់ថា៖ ករណីសរុបដែលរកឃើញអ្នកមានវីរុសកូវីដ-១៩ នៅក្នុងព្រឹត្តិការណ៍០៣វិច្ឆិកា គិតត្រឹមម៉ោង០៥:០០ល្ងាចនៃថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០ នេះ មានចំនួន ០៤នាក់។ ក្រុមការងារក្រសួងសុខាភិបាល កំពុងបន្តការយកវត្ថុសំណាកអ្នកប៉ះពាល់លើកទី២ និងកំពុងរង់ចាំលទ្ធផលដែលត្រូវផ្តល់មកក្រសួងជាបន្តបន្ទាប់ នៅពេលធ្វើការវិភាគរួច ដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ហើយក្រសួង នឹងបន្តជូនដំណឹងជូនសាធារណជនបន្តទៀត នៅពេលទទួលបានលទ្ធផលជាបន្តបន្ទាប់ និងប្រសិនបើមានការវិវត្តន៍ថ្មីៗពាក់ព័ន្ធទៅនៃព្រឹត្តការណ៍០៣វិច្ឆិកានេះ។

យោងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងសុខាភិបាល សូមឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិ ជាពិសេសសាលារាជធានីភ្នំពេញ ចាត់តាំងកម្លាំង ធ្វើការតាមដានការអនុវត្តការធ្វើចត្តាឡីស័ករបស់អ្នកប៉ះពាល់ទាំងអស់ទៅតាមដែនសមត្ថកិច្ចរបស់ខ្លួន ដោយរួមជាមួយមន្ទីរសុខាភិបាលរាជធានី-ខេត្ត ដែលពាក់ព័ន្ធ ដើម្បីចូលរួមត្រួតពិនិត្យ និងតាមដានសុខភាពអ្នកធ្វើចត្តាឡីស័កទាំងអស់ ប្រកបដោយការទទួលខុសត្រូវ និងរួមគ្នាទប់ស្កាត់ការចម្លងចូលក្នុងសហគមន៍ក្នុងទ្រង់ទ្រាយធំ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាលលេខ១១៥ដោយឥតគិតថ្លៃ។

ថ្ងៃចន្ទ ៩រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ចំនួន ០៣នាក់ និងមិនមានករណីជាសះស្បើយ
# នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

## ១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖

គិតត្រឹមម៉ោង ០៧:០០ព្រឹកថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជាមាន៖

- ចំនួនអ្នកព្យាបាលជាសះស្បើយសរុបទូទាំងប្រទេស មានចំនួន **២៨៨នាក់** (ស្មើនឹង ៩៦.០០% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះ មានស្រី ៥៨នាក់ និងបុរស ២៣០នាក់។
- អ្នកមានវីរុសកូវីដ-១៩ មានចំនួនសរុប **៣០០នាក់** (ស្ត្រី ៦០នាក់ និងបុរស ២៤០នាក់) ។
- អ្នកសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ ចំនួន **១២នាក់** (ស្រី ០២នាក់ និងបុរស ១០នាក់) ។

## ២. អ្នកដំណើរមកពីក្រៅប្រទេស ដែលមិនពាក់ព័ន្ធនឹងព្រឹត្តិការណ៍០៣វិច្ឆិកា

នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០ លទ្ធផលនៃការធ្វើតេស្តវត្ថុសំណាកសម្រាប់អ្នកដែលមិនពាក់ព័ន្ធនឹងព្រឹត្តិការណ៍០៣វិច្ឆិកា គឺ មិនមានអ្នកវិជ្ជមានវីរុសកូវីដ-១៩ ថ្មី និងមិនមានអ្នកជាសះស្បើយ។

## ៣. អ្នកប៉ះពាល់ ក្នុងព្រឹត្តិការណ៍០៣វិច្ឆិកា

នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០ ការធ្វើតេស្តអ្នកប៉ះពាល់ក្នុងព្រឹត្តិការណ៍០៣វិច្ឆិកា មានចំនួនសរុប ១១៦៦នាក់ (ទាំងតេស្តលើកទី១ និងលើកទី២) ដែលទទួលបានលទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ចំនួន ១១៤៣នាក់ មានដូចតទៅ៖

- អ្នកវិជ្ជមានវីរុសកូវីដ-១៩ មានចំនួន ០៣នាក់ (១. ឯកឧត្តម សួស យ៉ារ៉ា ២. លោក ស ចិត្រា និង៣. ឯកអគ្គរដ្ឋទូតហុងគ្រីប្រចាំកម្ពុជា និងវៀតណាម) កំពុងសម្រាកព្យាបាល នៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលក្រសួងបានចេញសេចក្តីប្រកាសព័ត៌មានរួចហើយកាលពីល្ងាចថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០។
- អ្នកអវិជ្ជមានវីរុសកូវីដ-១៩ មានចំនួន ១១៤០នាក់។
- នៅសល់វត្ថុសំណាកចំនួន២៣នាក់ទៀត ដែលនឹងត្រូវវិភាគបន្តដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០។

បើគិតទាំងបុរសជាអង្គរក្សផ្ទាល់គណប្រតិភូហុងគ្រី ដែលរកឃើញថា វិជ្ជមានវីរុសកូវីដ-១៩ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២០ ចំនួនសរុបអ្នកវិជ្ជមានវីរុសកូវីដ-១៩ នៅក្នុងព្រឹត្តិការណ៍០៣វិច្ឆិកា គឺមាន ០៤នាក់។

## ៤. ការក្រើនរំលឹករបស់ក្រសួងសុខាភិបាល

ក្រសួងសុខាភិបាល សូមធ្វើការក្រើនរំលឹកជូនដល់អ្នកដែលប៉ះពាល់ក្នុងព្រឹត្តិការណ៍០៣វិច្ឆិកា ទាំងអស់ ដែលមានលទ្ធផលតេស្តលើកទី១ និងលើកទី២ អវិជ្ជមានវីរុសកូវីដ-១៩ ចាំបាច់ត្រូវបន្តធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃនៅតាមផ្ទះឲ្យបានត្រឹមត្រូវ និងនៅសណ្ឋាគារប៉េស៊ីដង់សុខាភ្នំពេញ (សម្រាប់អ្នកដែលពុំមានលទ្ធភាពធ្វើចត្តាឡីស័កនៅផ្ទះខ្លួនឯង) ទៅតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងរបស់ក្រសួងសុខាភិបាលឲ្យបានហ្មត់ចត់ជាទីបំផុត ហើយកុំដើរចេញក្រៅផ្ទះ ឬពីសណ្ឋាគារ ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនេះឲ្យសោះ ដើម្បីទប់ស្កាត់ការចម្លងវីរុសដ៏កាចសាហាវនេះ ពីម្នាក់ទៅម្នាក់ និងចូលក្នុងសហគមន៍។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លងសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអង្គារ ១០រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩